ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំនព្វមាស និងទិសដៅការងារសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២១

នៅក្នុងរយៈពេល៩ខែ ឆ្នាំ២០២១នេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំបំពេញការងារយ៉ាងសកម្ម តាមបែបគន្លងថ្មីលើវិស័យការងារសំខាន់ៗជាច្រើន ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ និងសមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនដោយទទួលបានលទ្ធផលសំខាន់ៗដូចខាងក្រោម៖

**I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖**

**១- មុខងារនីតិកម្ម**

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន០៧លើក ប្រជុំពេញអង្គ និងប្រជុំព្រឹទ្ធសភាជាវិសាមញ្ញ នីតិកាលទី៤ ចំនួន០៣លើក ដែលមានរបៀបវារៈដូចខាងក្រោម៖

១-ពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១២ច្បាប់

២-ពិនិត្យ និងសម្រេចលើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២០

៣-ពិនិត្យនិងសម្រេចលើគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២១

៤-ពិនិត្យរបាយការណ៍ស្តីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៤

៥-ការប្រកាសទទួលស្គាល់លោកជំទាវ **ទេព សំអូន** ជាសមាជិកាព្រឹទ្ធសភា នីតិកាលទី៤ មណ្ឌលភូមិភាគទី៦ (ខេត្តព្រៃវែង និងខេត្តស្វាយរៀង) ជំនួសឯកឧត្តម **សុខ យាត** ដែលបានទទួលមរណភាព និងការជ្រើសរើសឯកឧត្តម **អ៊ឹង លាងហ៊ួ** ជាសមាជិកគណៈកម្មការអប់រំ យុវជន កីឡា ធម្មការ សាសនា វប្បធម៌ វិចិត្រសិល្បៈ និងទេសចរណ៍ ព្រឹទ្ធសភា នីតិកាលទី៤

- បានរៀបចំចាត់ចែងជូនសមាជិក សមាជិកាព្រឹទ្ធសភា ប្រជុំជាមួយតំណាងរាជរដ្ឋាភិបាលតាមប្រព័ន្ធវីដេអូ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន១២ច្បាប់

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមប្រជុំស្តីពី ការឈ្វេងយល់អំពីការកសាងក្របខណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈ សម្រាប់រៀបចំសេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២២ តាមប្រព័ន្ធវីដេអូផ្សាយចេញពីរដ្ឋសភា

- បានទទួលសេចក្តីព្រាងច្បាប់ចំនួន១២ច្បាប់ ពីរាជរដ្ឋាភិបាល និងរដ្ឋសភា

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស សេចក្តីសម្រេច សេចក្តីជូនដំណឹង របាយការណ៍ និងលិខិតផ្សេងៗចំនួន១,០០៦ច្បាប់

-បានសិក្សាស្រាវជ្រាវ និងផលិតឯកសារជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ចំនួន១២ច្បាប់

- បានធ្វើកំណត់បង្ហាញព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច សារាចរណែនាំ ប្រកាស របាយការណ៍ និងលិខិតផ្សេងៗចំនួន២០២ច្បាប់

- បានធ្វើបច្ចុប្បន្នភាពគេហទំព័រ (Laws.gov.kh) ប្រមូលព័ត៌មានទាក់ទងនឹងច្បាប់ អនុក្រឹត្យ ព្រះរាជក្រឹត្យ និងច្បាប់ដែលបានធ្វើវិសោធនកម្ម និងអនុម័តរួចៗ

**២- មុខងារតាមដានការអនុវត្តច្បាប់**

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញជួបពិភាក្សាការងារជាមួយឯកឧត្តម **គៀត ច័ន្ទថារិទ្ធ** អគ្គនាយកអន្តោប្រវេសន៍ នៃក្រសួងមហាផ្ទៃ, មន្ត្រីជំនាញការិយាល័យ អប់រំ យុវជន និងកីឡា ខណ្ឌចំការមន, និងមន្ត្រីរដ្ឋបាលខេត្តក្រចេះចំនួន០៣លើក ដើម្បីឈ្វេងយល់អំពីវិស័យជំនាញជាសមត្ថកិច្ចរបស់គណៈកម្មការ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មចំនួន១០លើក ដើម្បីសិក្សាឈ្វេងយល់អំពីប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលពាក់ព័ន្ធលើកិច្ចប្រតិបត្តិការរបស់អភិបាលនៃគណៈអភិបាលខេត្ត កងកម្លាំងប្រដាប់អាវុធទាំង៣ប្រភេទរបស់ខេត្ត មន្ទីរទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច និងមន្ទីរមុខងារសាធារណៈ និងបញ្ហាប្រឈមនានា នៅខេត្តកោះកុង, សិក្សាឈ្វេងយល់អំពីវឌ្ឍនភាពលើការងារភូមិ ឃុំ សង្កាត់ មានសុវត្ថិភាព ការងារបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ ប្រមូលព័ត៌មានបញ្ហាប្រឈម និងសំណូមពរផ្សេងៗ នៅខេត្តកណ្តាល, សិក្សាឈ្វេងយល់ពីបញ្ហាប្រឈមការបម្រើសេវាសាធារណៈ ការងារអត្រានុកូលដ្ឋាន និងការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការ ព្រមទាំងតាមដានការសិក្សា និងចងក្រងឯកសារទីតាំងដីដែលប្រជាពលរដ្ឋកំពុងប្រើប្រាស់អាស្រ័យផលយូរអង្វែងលើតំបន់ការពារធនធានធម្មជាតិ និងតំបន់របៀងអភិរក្សជីវចម្រុះ នៅខេត្តឧត្តរមានជ័យ, សិក្សាឈ្វេងយល់អំពីការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ

ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ ការអភិវឌ្ឍមូលដ្ឋាន នៅខេត្តព្រៃវែង និងខេត្តស្វាយរៀង និងប្រមូលព័ត៌មាន ផ្សព្វផ្សាយច្បាប់ តាមដានការអនុវត្តច្បាប់ ដោយផ្តោតលើបញ្ហាលើកកម្ពស់សមភាពយេនឌ័រ និងសុខភាពសាធារណៈ ការរស់នៅ និងការធ្វើការងារតាមគន្លងថ្មីស្របតាមបរិបទកូវីដ-១៩ ព្រមទាំងសិក្សាឈ្វេងយល់អំពីវិស័យពាក់ព័ន្ធនឹងសមត្ថកិច្ចរបស់គណៈកម្មការ នៅខេត្តរតនគិរី ខេត្តកំពង់ចាម និងខេត្តតាកែវ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះបំពេញបេសកកម្មជាមួយប្រតិភូក្រសួងបរិស្ថាន ដើម្បីពិភាក្សាលើករណីប្រជាពលរដ្ឋដែលកាន់កាប់ និងអាស្រ័យផលនៅក្នុងដែនជំរកសត្វព្រៃភ្នំត្នោត និងភ្នំពក នៅឃុំស្ពោ ស្រុកសង្គមថ្មី ខេត្តព្រះវិហារ

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំក្រុមអ្នកច្បាប់រាជធានីភ្នំពេញ និងក្រុមអ្នកច្បាប់មកពីខណ្ឌទាំង១៤ និងកិច្ចប្រជុំក្រុមប្រឹក្សាជាតិ ព្រមទាំងកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិជាតិនៃសម្ព័ន្ធភាពជាតិ ក្រុមប្រឹក្សាថ្នាក់មូលដ្ឋានក្នុងគោលបំណងដើម្បីពិនិត្យមើលអំពីវឌ្ឍនភាព និងបញ្ហាប្រឈមនានា ដែលសម្ព័ន្ធភាពជាតិបានអនុវត្តកន្លងមក ព្រមទាំងពិនិត្យ និងអនុម័តលើផែនការសកម្មភាពការងារ និងថវិកាសម្រាប់អនុវត្តនៅឆ្នាំបន្ទាប់ៗ

**៣- មុខងារតំណាង**

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងកិច្ចប្រជុំពិភាក្សាការងាររវាង**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយឯកឧត្តម **ស៊ុន ចាន់ថុល** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន

- បានផ្តល់សេវា និងអមដំណើរថ្នាក់ដឹកនាំព្រឹទ្ធសភា ចុះបំពេញការងារ ជួបសំណេះសំណាលសាកសួរសុខទុក្ខ នាំយកអំណោយចែកជូនអាជ្ញាធរ កងកម្លាំង ជាពិសេសប្រជាពលរដ្ឋក្រីក្រជួបការលំបាក នាំយកគ្រឿងឧបភោគ បរិភោគ ចង្ហាន់បិណ្ឌបាត្រ បច្ច័យមួយចំនួនប្រគេនព្រះសង្ឃ និងចូលរួមគោរពវិញ្ញាណក្ខន្ធ ព្រមទាំងចូលរួមក្នុងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន៦៩លើក

- បានរៀបចំបែបបទ ផ្តល់សេវា និងអមដំណើរសមាជិកព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋ ក្រុមគ្រូពេទ្យ ក្រុមប្រឹក្សាឃុំ សង្កាត់ និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងនាំយកគ្រឿងឧបភោគ បរិភោគ ម៉ាស់ អាល់កុល និងថវិកាមួយចំនួនចែកជូនប្រជាពលរដ្ឋដែលកំពុងជួបការលំបាក និងរងគ្រោះមហន្តរាយផ្សេងៗ ជាពិសេសប្រជាពលរដ្ឋដែលកំពុងមានជំងឺកូវីដ-១៩ ផ្សព្វផ្សាយវិធានការរបស់ក្រសួងសុខាភិបាល ដើម្បីចូលរួម

យុទ្ធនាការប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩ និងនាំយកទេយ្យទាន បច្ច័យប្រគេនព្រះសង្ឃនៅតាមទីវត្តអារាមនានា ព្រមទាំងបានបំពេញការកិច្ចផ្សេងៗទៀតនៅមូលដ្ឋាន រាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងចំនួន១,០៦២លើក

- បានសហការរៀបចំវេទិកាថ្នាក់ស្រុកចំនួន០២លើក នៅស្រុកកងមាស និងស្រុកកោះសូទិន ខេត្តកំពង់ចាម ស្តីពី ការលើកកម្ពស់ការផ្តល់សេវាសាធារណៈឱ្យមានប្រសិទ្ធភាព តម្លាភាព និងការអភិវឌ្ឍមូលដ្ឋាន និងបានរៀបចំពិធីសំណេះសំណាលចំនួន០១លើក នៅស្រុកវើនសៃ ខេត្តរតនគិរី ជាមួយប្រធានក្រុមប្រឹក្សាឃុំ នាយប៉ុស្តិ៍នគរបាល រដ្ឋបាលឃុំ ស្មៀនឃុំ សមាជិកក្រុមប្រឹក្សាឃុំទទួលបន្ទុកកិច្ចការស្ត្រី និងកុមារ និងអាជ្ញាធរស្រុក មានអ្នកចូលរួមសរុបចំនួន ១៩៦នាក់

- បានរៀបចំ និងចាត់ចែងពិធីបូជាសព និងបុណ្យសព **ឯកឧត្តម សុខ យាត** សមាជិកគណៈ-កម្មការទី៧ ព្រឹទ្ធសភា នៅវត្តសុវណ្ណរង្សី ភូមិលេខ៤ សង្កាត់កំពង់លាវ ក្រុងព្រៃវែង ខេត្តព្រៃវែង

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានធ្វើបាឋកថាស្តីពី តួនាទី ភារកិច្ចព្រឹទ្ធសភាកម្ពុជា សមិទ្ធផល ការប្រឈម និងមាគ៌ាឆ្ពោះទៅកាន់សភាទំនើបជូនសិស្សមន្ត្រី និងកម្មសិក្សាការីទាំងអស់នៃសាលាភូមិន្ទរដ្ឋបាលចំនួន១,០០០នាក់ និងធ្វើបទឧទ្ទេសនាមស្តីពី តួនាទីរបស់ព្រឹទ្ធសភា ជូននិស្សិតនៃសាកលវិទ្យាល័យអាស៊ី-អឺរ៉ុប តាមប្រព័ន្ធវីដេអូចំនួន០២លើក ព្រមទាំងបានអញ្ជើញជួបសំណេះសំណាល សាកសួរសុខទុក្ខ និងនាំយកអំណោយទៅប្រគល់ជូនសង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ ដើម្បីទុកជូនអាជ្ញាធរសង្កាត់ចែកជូនប្រជាពលរដ្ឋងាយរងគ្រោះចំនួន០៩លើក

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភាតំណាងដ៏ខ្ពង់ខ្ពស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា** អញ្ជើញចូលរួមពិធីកាន់បិណ្ឌវេនទី១ នៅវត្តនាគវ័ន និងនាំយកអំណោយចំនួន៥០០ឃីត ជូនដល់សង្កាត់ទាំង៥ ក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

- ក្នុងឱកាសពិធីបុណ្យកាន់បិណ្ឌ និងបុណ្យភ្ជុំបិណ្ឌប្រពៃណីជាតិខ្មែរ អគ្គលេខាធិការ-ដ្ឋានព្រឹទ្ធសភា បានរៀបចំ និងផ្តល់សេវាជូនតំណាងដ៏ខ្ពង់ខ្ពស់របស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និងលោកជំទាវៈ

+នាំយកបច្ច័យ ទេយ្យទាន គ្រឿងឧបភោគ បរិភោគ រួមមានៈ អង្ករ២តោន ទឹកក្រូច៣០កេះ ទឹកសុទ្ធ៥០កេះ ត្រី២៥កេះ មីយើង៥កេះធំ តែ១០គីឡូក្រាម នំខ្មែរ១៧កន្ត្រក សាជក២១៤កញ្ចប់ ផ្លែឈើ៨កន្ត្រកធំ ក្រណាត់ស៤៥ដុំ ដោយចំណាយបច្ច័យសរុបអស់ ២៥.៣០០.០០០រៀល និងប្រាក់ដុល្លារ១០.៦០០$ និងថវិកាចំនួន៤.៣៥០$ សហរដ្ឋអាមេរិក

សម្រាប់កសាងវត្ត ព្រមទាំងគ្រឿងឧបភោគ បរិភោគផ្សេងទៀតទៅវេរប្រគេនព្រះសង្ឃក្នុងពិធីកាន់បិណ្ឌ នៅវត្តនាគវ័ន វត្តវាលស្បូវ វត្តអង្គបឹងចក និងវត្តបទុមវតី រាជធានីភ្នំពេញ

+នាំយកទេយ្យទាន គ្រឿងឧបភោគ បរិភោគ ភេសជ្ជៈ ផ្លែឈើជាច្រើនមុខ ដើម្បីចូលរួមក្នុងពិធីកាន់បិណ្ឌវេនទី១២ នៅវត្តវិសុទ្ធវង្សរាកណ្ដាលកោះសូទិន និងវត្តត្នោត។ ក្នុងឱកាសនោះដែរ សម្ដេចក៏បានផ្ដល់នូវអង្ករចំនួន២តោន និងថវិកាចែកជូនប្រជាពលរដ្ឋក្រីក្រសរុបទឹកប្រាក់ចំនួន២៣.០០០.០០០រៀល និងចូលរួមប្រារព្ធពិធីសូត្រមន្តឆ្លងសាលាបុណ្យមួយខ្នងជាអំណោយផ្ទាល់របស់សម្ដេច និងលោកជំទាវ ជូនប្រជាពលរដ្ឋ នៅឃុំកោះសូទិន ស្រុកកោះ-សូទិន ខេត្តកំពង់ចាម

- បានរៀបចំអំណោយរបស់**សម្ដេចវិបុលសេនាភក្ដី សាយ ឈុំ ប្រធានព្រឹទ្ធសភា** និងលោកជំទាវ ចែកជូនមន្ត្រីរាជការ និងកងកម្លាំងការពារសន្តិសុខសណ្ដាប់ធ្នាប់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា, សមាគមចលនាវប្បធម៌ជាតិ ដើម្បីកុមារកំព្រា កុមារក្រីក្រ, ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាតចំនួន១,៥៩៩គ្រួសារ និងប្រជាពលរដ្ឋដែលកំពុងធ្វើចត្តាឡីស័កចំនួន៦៨៩នាក់ នៅមណ្ឌលចំនួន០៦កន្លែង ក្នុងរាជធានីភ្នំពេញ

- បានរៀបចំអំណោយរបស់**ឯកឧត្តមកិត្តិសង្គហបណ្ឌិត ទេព ងន អនុប្រធានទី២ ព្រឹទ្ធសភា** ប្រគល់ជូនអាជ្ញាធរចែកជូនប្រជាពលរដ្ឋខ្វះខាតជួបការលំបាក ចត្តាឡីស័ក និងមានជំងឺប្រចាំកាយ នៅរាជធានីភ្នំពេញ ខេត្តកណ្ដាល ខេត្តតាកែវ ខេត្តកោះកុង និងខេត្តពោធិ៍សាត់ ព្រមទាំងបាននាំយកទេយ្យទាន ទានព្រះវស្សា និងបច្ច័យមួយចំនួនទៅប្រគេនព្រះសង្ឃនៅខេត្តតាកែវ ខេត្តពោធិ៍សាត់ និងខេត្តព្រៃវែង

- បានរៀបចំអំណោយ និងថវិកាមួយចំនួនឧបត្ថម្ភមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលកើតជំងឺកូវីដ-១៩ ចំនួន៣៣នាក់ និងចត្តាឡីស័កចំនួន៦០នាក់

- បានឧបត្ថម្ភថវិកាមួយចំនួនជូនកាកបាទក្រហមកម្ពុជា និងក្រុមគ្រូពេទ្យដែលបានចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ ជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា ព្រមទាំងថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានរៀបចំគ្រឿងសក្ការបូជាសម្រាប់រាប់បាត្រប្រគេនព្រះសង្ឃចំនួន៣០កញ្ចប់ ក្នុងពិធីបុណ្យមាឃបូជា និងរៀបចំអំណោយចំនួន៣០កញ្ចប់ ជូនគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ សម្រាប់ចុះសួរសុខទុក្ខអ្នកជំងឺ កុមារកំព្រា និងជនក្រីក្រ

- បានទទួលពាក្យបណ្ដឹងចំនួន៣៧ករណី ធ្វើកំណត់បង្ហាញពាក្យបណ្ដឹងចំនួន៣១ករណី ធ្វើលិខិតអន្តរាគមន៍ទៅក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយចំនួន៣១ករណី បញ្ជូនពាក្យបណ្ដឹង

ទៅក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែនចំនួន០២ករណី ឆ្លើយតបទៅម្ចាស់បណ្តឹងចំនួន៣៧ករណី ទទួលលិខិតឆ្លើយតបអំពីការដោះស្រាយពាក្យបណ្តឹងរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន១១ករណី និងតម្កល់ទុកមិនចាត់ការចំនួន០២ករណី ទទួលឯកសារពាក្យបណ្តឹងដែលក្រសួង ស្ថាប័នពាក់ព័ន្ធចម្លងជូនមកគណៈកម្មការដើម្បីជូនជ្រាបចំនួន១៣ករណី និងដោះស្រាយបញ្ចប់ចំនួន ០១ករណី

- បានទទួលមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចូលអានសៀវភៅនៅបណ្ណាល័យព្រឹទ្ធសភាចំនួន៧០នាក់ ព្រមទាំងបានអនុញ្ញាតឱ្យខ្ចីសៀវភៅចំនួន១៦ក្បាល និងសងវិញចំនួន ០៧ក្បាល

- បានទទួលម៉ាស់ចំនួន៩,០០០ម៉ាស់ ជាអំណោយដ៏ថ្លៃថ្លារបស់**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រមុខរដ្ឋស្តីទីនៃព្រះរាជាណាចក្រកម្ពុជា** ដើម្បីចូលរួមប្រយុទ្ធប្រឆាំងជំងឺកូវីដ-១៩

- បានទទួលសៀវភៅពីអង្គការមូលនិធិអាស៊ីចំនួន២៧៧ក្បាល

- បានផលិតទស្សនាវដ្តីប្រចាំខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ ចំនួន៧,២០០ក្បាល

- បានផលិតសៀវភៅបត់ស្តីពី មុខងារនីតិកម្មព្រឹទ្ធសភាចំនួន១,០០០ក្បាល

- បានផលិតប័ណ្ណរថយន្តចេញ-ចូលព្រឹទ្ធសភាឆ្នាំ២០២២ របស់សមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៣,៨០០សន្លឹក

- បានធ្វើលិខិតអបអរសាទរជូន**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**ចំនួន០២លើក ក្នុងឱកាសដែលសម្តេចទទួលគ្រឿងឥស្សរិយយសថ្នាក់ "មិត្តភាព Order of Friendship" ពីឯកឧត្តម **Vladimir Putin** ប្រធានាធិបតីនៃសហព័ន្ធរុស្ស៊ី និងក្នុងឱកាសប្រកបដោយកិត្តិយសទទួលបានមេដាយមាសសន្តិភាពពិភពលោកពីមហាសន្និបាតនៃក្តីសង្ឃឹមលើកទី៧

- បានធ្វើសារលិខិតថ្វាយព្រះពរ**សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ** និងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងជូនពរ**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងថ្នាក់ដឹកនាំតាមក្រសួង ស្ថាប័ននានាចំនួន ៤១លើក

- បានធ្វើសាររំលែកទុក្ខជូនសមាជិកព្រឹទ្ធសភា និងឥស្សរជននានាចំនួន២៧លើក។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងជម្រាបលាជូន**សម្តេចវិបុលសេនាភក្តី សាយ ឈុំ ប្រធានព្រឹទ្ធសភា** ជាមួយគណៈប្រតិភូជាតិ-អន្តរជាតិ និងអង្គទូតនានាចំនួន០៩លើក

- បានរៀបចំទីកន្លែង និងផ្តល់សេវាក្នុងពិធីជំនួបសម្តែងការគួរសម និងជម្រាបលា ព្រមទាំងពិភាក្សាការងារជូនសមាជិកព្រឹទ្ធសភា ជាមួយគណៈប្រតិភូជាតិ និងអន្តរជាតិនានាចំនួន២៣លើក

- ឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា បានអនុញ្ញាតឱ្យភ្ញៀវជាតិ និងអន្តរជាតិនានា ចូលជួបសម្តែងការគួរសម និងជម្រាបលាចំនួន០៦លើក

- បានរៀបចំចាត់ចែងជូនសមាជិកព្រឹទ្ធសភា និងអគ្គលេខាធិការព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំអន្តរជាតិនានា (APF, APPF, IPU, AIPA, CLV, ASEP, ASGP, APA) តាមប្រព័ន្ធវីដេអូចំនួន ៣១លើក

- បានរៀបចំបែបបទជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមវេទិកាសមាជិកសភាអាស៊ី-ប៉ាស៊ីហ្វិច ទទួលបន្ទុកសុខភាពពិភពលោក (APPFGH) តាមប្រព័ន្ធវីដេអូ

- បានចូលរួមទិវា ITECH រៀបចំដោយស្ថានទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា និងចូលរួមខួបលើកទី២៨ នៃថ្ងៃប្រកាសរដ្ឋធម្មនុញ្ញ តាមប្រព័ន្ធវីដេអូ

- បានរៀបចំកម្មវិធីកិច្ចសន្ទនាអនឡាញស្តីពី ខួប៦៣ឆ្នាំ ទំនាក់ទំនងការទូតកម្ពុជា-ចិន រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងស្ថានទូតចិនប្រចាំកម្ពុជា និងសមាគមអ្នកស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន

- បានរៀបចំពិធីជូនលោកជំទាវប្រធានគណៈកម្មការទី៩ ព្រឹទ្ធសភា ទទួលគ្រឿងឥស្សរិយយសពីសាធារណរដ្ឋបារាំង

- បានបង្កើតក្រុមមិត្តភាពព្រឹទ្ធសភាជាមួយព្រឹទ្ធសភាប៉ាគីស្ថាន និងក្រុមព្រឹទ្ធសភាទទួលបន្ទុក (ASEP)

- បានរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ចំនួន០២លើក ស្តីពីកិច្ចសហប្រតិបត្តិការរវាងគណៈកម្មការទី១ព្រឹទ្ធសភាជាមួយក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន និងពិធីចុះហត្ថលេខាលើអនុស្សរណៈ(MOU)រវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានរដ្ឋសភាជាមួយវិទ្យាស្ថានសភាអាស៊ី (PCA)

- បានសម្របសម្រួល និងរៀបចំបែបបទទទួលឱសថបុរាណចិន "LIANHUA QINGWEN" ចំនួន៤០០ប្រអប់ ពីស្ថានទូតនៃសាធារណរដ្ឋប្រជាមានិតចិន និងម៉ាស់ចំនួន៣៦៨,០០០ម៉ាស់ ពីលោក Lee Jung-geun ប្រធានសហព័ន្ធសហគ្រាសធុនតូចប្រចាំព្រះរាជាណាចក្រកម្ពុជា

- បានសហការ និងទំនាក់ទំនងជាមួយស្ថានទូតឥណ្ឌា, ស្ថានទូតចិន, ស្ថានទូតហ្វីលីពីន, ស្ថានទូតម៉ាឡេស៊ី, អគ្គលេខាធិការដ្ឋានរដ្ឋសភា,ទីស្ដីការគណៈរដ្ឋមន្ត្រី, ដៃគូភាគីចិន, អង្គការមូលនិធិអាស៊ី, មូលនិធិចិនដើម្បីសន្តិភាព និងការអភិវឌ្ឍ, អង្គការចៃកា(JICA), ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិកូរ៉េ(KOICA), ភ្នាក់ងារកិច្ចសហប្រតិបត្តិការអន្តរជាតិរបស់ព្រះរាជាណាចក្រថៃ(TICA), ភ្នាក់ងារសង្គមព័ត៌មានជាតិ(NIA), ក្រុមប្រឹក្សាអភិវឌ្ឍសេដ្ឋកិច្ច(CDC), មជ្ឈមណ្ឌលអភិវឌ្ឍន៍ធនធានមនុស្សនៃសាធារណរដ្ឋកូរ៉េ(HRD), វិទ្យាស្ថានសាន់ហ៉ាយស៍, វិទ្យាស្ថានសភាអាស៊ី (PCA), វិទ្យាស្ថានជាតិប្រៃសណីយ៍ ទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន (NIPTICT), វិទ្យាស្ថានជាតិស្ថិតិ(NIS), សមាគមត្រាជូ, សហគមន៍ស្រាវជ្រាវវឌ្ឍនភាពកម្ពុជា-ចិន, ក្រុមហ៊ុនKOHA, ក្រុមហ៊ុនCambodia Hosting និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍ វគ្គបណ្ដុះបណ្ដាល ព្រមទាំងការរៀបចំពិធីផ្សេងៗ។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

- បានសហការ និងសម្របសម្រួលការចាក់វ៉ាក់សាំងប្រឆាំងនឹងជំងឺកូវីដ-១៩ (លើកទី១ ទី២ និងទី៣) ជូនសម្ដេច ព្រះអង្គម្ចាស់ លោកជំទាវ ព្រមទាំងថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា, ថ្នាក់ដឹកនាំ សមាជិក សមាជិកាក្រុមប្រឹក្សាធម្មនុញ្ញ, ទីប្រឹក្សារបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា, ថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងរៀបចំបែបបទ និងសម្របសម្រួលការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ (ដូសទី១) ជូនកូនចៅរបស់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រកបដោយជោគជ័យ

- បានប្រជុំកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំកម្រិតបច្ចេកទេស និងនយោបាយជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អំពីគម្រោងថវិកាឆ្នាំ២០២២ របស់ព្រឹទ្ធសភា

- បានប្រជុំរៀបចំផែនការការងារសំខាន់ៗរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដើម្បីធានានិរន្តភាព និងប្រសិទ្ធភាពក្នុងបរិបទជំងឺកូវីដ-១៩

- បានប្រជុំត្រួតពិនិត្យវឌ្ឍនភាពការងារនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី១ ទី២ និងទី៣ ឆ្នាំ២០២១

- បានប្រជុំពិនិត្យ និងផ្ដល់យោបល់លើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្រសវនកម្មផ្ទៃក្នុងរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (២០២១-២០២៣) និងផែនការសវនកម្មផ្ទៃក្នុងប្រចាំឆ្នាំ២០២១

- បានប្រជុំគណៈកម្មការវាយតម្លៃស្ថានភាពបាត់បង់សម្បទាវិជ្ជាជីវៈមន្ត្រីរាជការ, គោលការណ៍

ផ្តល់គ្រឿងឥស្សរិយយសជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងគោលការណ៍គ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំស្តីពី គោលការណ៍ដំឡើងឋានន្តរស័ក្តិ ថ្នាក់តាមកម្រិតសញ្ញាបត្រមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានប្រជុំគណៈកម្មការនានានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១០លើក

- បានសិក្សា និងធ្វើបច្ចុប្បន្នភាពគោលការណ៍ និងគោលនយោបាយនានា ឱ្យបានសមស្របនឹងដំណាក់កាលថ្មី

- បានបង្កើតគណៈកម្មការដើម្បីពិនិត្យ និងសិក្សាអំពីតួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់អង្គភាពកិច្ចការសុខភាព និងសង្គមកិច្ចនៃព្រឹទ្ធសភា

- ការអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភារួមមានៈ ចំណេះដឹងជំនាញ ភាសាបរទេស ការដឹកនាំ/គ្រប់គ្រង និងបច្ចេកវិទ្យាព័ត៌មាន។

**៥.១-ការងាររដ្ឋបាល និងហិរញ្ញវត្ថុៈ**

- យោងតាមសារាចរណែនាំស្តីពី ការធ្វើវិចារណកម្ម និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានប្រជុំជាមួយគណៈកម្មការទី២ព្រឹទ្ធសភា ដើម្បីកាត់បន្ថយការចំណាយប្រតិបត្តិការ សំដៅចូលរួមជាមួយរាជរដ្ឋាភិបាលក្នុងការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងទប់ទល់ផលប៉ះពាល់ជាអវិជ្ជមានមកលើសេដ្ឋកិច្ចជាតិ

- បានទទួលលិខិតចូលចំនួន៥,៩១៨ច្បាប់ និងបញ្ជូនលិខិតចេញចំនួន២,២៤៤ច្បាប់

- បានផលិតរបាយការណ៍ស្តីពី សកម្មភាពការងាររបស់ព្រឹទ្ធសភានៅចន្លោះសម័យប្រជុំលើកទី៦ និងលើកទី៧ នីតិកាលទី៤

- បានបាញ់ថ្នាំសម្លាប់មេរោគតាមអគារនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩

- បន្តយកចិត្តទុកដាក់ចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ការងាររក្សាអនាម័យបរិស្ថាន សំរាម សួនច្បារ និងការដាំដើមឈើ ប្រព័ន្ធទឹក លូ ថ្នល់ និងចំណតរថយន្ត ដើម្បីធានាឱ្យមានផាសុកភាព និងបរិស្ថានបៃតង

- បានធ្វើរបាយការណ៍ទូទាត់ថវិការបស់ព្រឹទ្ធសភាឆ្នាំ២០២០ និងរៀបចំគោលការណ៍បែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភា ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- ការធ្វើវិចារណកម្មថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងការពង្រឹងប្រសិទ្ធភាពចំណាយសម្រាប់អនុវត្តច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២១

- បានរៀបចំយុទ្ធសាស្ត្រថវិកាព្រឹទ្ធសភា៣ឆ្នាំរំកិល (២០២២-២០២៤) និងគម្រោងថវិកាព្រឹទ្ធសភា ឆ្នាំ២០២២

- បានរៀបចំរបាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភា ឆមាសទី១ ឆ្នាំ២០២១ ជូនគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា

- បានបើកប្រាក់បៀវត្សប្រចាំខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ ប្រាក់ឧបត្ថម្ភបុណ្យចូលឆ្នាំថ្មីប្រពៃណីជាតិខ្មែរ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ទីប្រឹក្សា ជំនួយការ អ្នកបើកបរ និងនិវត្តជននៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានដេញថ្លៃការផ្គត់ផ្គង់ការបោះពុម្ព សម្ភារការិយាល័យ សម្ភារអនាម័យ និងឯកសណ្ឋាន

- បង្កើន 3E's ដោយយកការសន្សំសំចៃ និងវិចារណកម្មថវិកាជាស្នូល

- បានរៀបចំតបណ្តាញប្រព័ន្ធ(FMIS) បំពាក់សម្ភារ ការប្រើប្រាស់ និងប្រជុំតាមប្រព័ន្ធវីដេអូ

- បានរៀបចំលិខិតបទដ្ឋានគតិយុត្តផ្សេងៗចំនួន៥៨០ច្បាប់ និងធ្វើប័ណ្ណសម្គាល់ខ្លួនចំនួន១២៧ប័ណ្ណ

- បានរៀបចំស្នើគ្រឿងឥស្សរិយយសជូនសមាជិកព្រឹទ្ធសភា សម្រាប់ពាក់កណ្តាលនីតិកាលទី៤

- បានប្រគល់គ្រឿងឥស្សរិយយស មេដាយការងារជូនមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានស្នាដៃឆ្នើមសម្រាប់ឆ្នាំ២០១៩ និងឆ្នាំ២០២០

- បានវាយតម្លៃសមត្ថភាពមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលគ្រប់លក្ខណៈសម្បត្តិត្រៀមតម្លើងថ្នាក់បៀវត្ស

- បានស្រង់ស្ថិតិមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ដែលពិការភាព កំពុងបម្រើការងារនៅអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានធ្វើបច្ចុប្បន្នភាពគោលការណ៍គ្រប់គ្រង និងការប្រើប្រាស់បុគ្គលិកជាប់កិច្ចសន្យានៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បានបើកវគ្គបណ្តុះបណ្តាលក្នុងប្រទេសចំនួន២១វគ្គ មានសិក្ខាកាមចូលរួមចំនួន៣១៤នាក់ និងសិក្ខាសាលាក្នុងប្រទេសចំនួន០៤លើក មានសិក្ខាកាមចូលរួមចំនួន១៦៦នាក់

- បានទទួលអាហារូបករណ៍ពីសាកលវិទ្យាល័យនានាចំនួន៤០កន្លែង មានសិក្ខាកាមចូលរួមចំនួន០៧កន្លែង

- បានទទួលអាហារូបករណ៍ចំនួន២៨កន្លែង លើជំនាញ Digital Skill Essential នៅវិទ្យាស្ថានជាតិប្រៃសណីយ៍ គមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មាន

- បានរៀបចំពិធីបិទវគ្គបណ្តុះបណ្តាលស្តីពី បច្ចេកទេសក្នុងការសរសេរឯកសារសម្រាប់គាំទ្រកិច្ចប្រជុំ (ASEP11)

- បានធ្វើសេចក្តីជូនដំណឹងផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលភាសាអង់គ្លេសកម្រិតមធ្យម និងការផ្តល់អាហារូបករណ៍ជប៉ុន(JDS) ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងថ្នាក់បណ្ឌិត

- បានស្រាវជ្រាវ និងប្រមូលឯកសារពាក់ព័ន្ធ ដើម្បីរៀបចំកសាងគោលនយោបាយអភិវឌ្ឍធនធានមនុស្សរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានធ្វើផែនការសកម្មភាពបណ្តុះបណ្តាលរយៈពេល១០ឆ្នាំ របស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា (ឆ្នាំ២០២១-២០៣០)

- បានសាងសង់អគារ១ខ្នង កម្ពស់៣ជាន់ សម្រាប់ជាការិយាល័យធ្វើការរបស់នាយកដ្ឋានព័ត៌មានវិទ្យា

- បានកសាងបន្ទប់អានសម្រាប់បណ្ណាល័យអេឡិចត្រូនិច បំពាក់សម្ភារ និងកន្លែងCoffee

- បានសង់រោងដែកសម្រាប់ដាក់ម៉ាស៊ីនភ្លើង, សង់ឃ្លាំងដាក់សម្ភារ, រៀបការ៉ូបាតបន្ទប់ស្នាក់នៅរបស់មន្ត្រីសេវាកម្ម និងអ្នកបើកបរ, ប្រក់ដំបូលស័ង្កសីពាសអ៊ីសូឡង់ការពារដំដៅថ្ងៃលើដំបូលសាលប្រជុំពិសេស៣, ប្រក់ដំបូលស័ង្កសីជ័រថ្លា និងរៀបចំកន្លែង Coffee Counter នៅខាងមុខសាលសិក្ខាសាលាខាងត្បូង ផ្នែកខាងមុខសាលអានបណ្ណាល័យ, បាំងកញ្ចក់ធ្អឹងដែកសម្រាប់ធ្វើជាបន្ទប់ប្រជុំនៅខាងមុខនាយកដ្ឋានស្រាវជ្រាវវិការ, ធ្វើបញ្ចរថ្មម៉ាបស្លាកឈ្មោះព្រឹទ្ធសភាដាក់នៅខាងមុខអគារក្រហម ព្រមទាំងបានបំពាក់តុឈើប្រជុំថ្មីបន្ថែម នៅសាលប្រជុំអចិន្ត្រៃយ៍ព្រឹទ្ធសភាចំនួន១០គ្រឿង

- បានជួសជុល និងគូសគំនូសចំណតរថយន្ត និងសញ្ញាចរាចរណ៍ នៅតាមចំណតនានាក្នុងបរិវេណព្រឹទ្ធសភា

- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ និងផ្កានៅតាមសួននានា ព្រមទាំងកាប់គ្រៀវមែកឈើ និងដាំដើមឈើក្នុងបរិវេណព្រឹទ្ធសភាចំនួន៩២លើក

- បានទទួលរថយន្តអគ្គិសនីសម្រាប់បោសសំរាមចំនួន០២គ្រឿង, រថយន្តដឹកសំរាមចំនួន០១គ្រឿង, រថយន្តសម្រាប់ឡើងទីខ្ពស់ចំនួន០១គ្រឿង និងរថយន្តបោសលាងសម្អាតថ្នល់ចំនួន០១គ្រឿង

- បានជួសជុលបណ្តាញលូ ដាក់ខ្ទោះមុខទឹកភ្លៀង និងបូមស្តារលាងសម្អាតប្រព័ន្ធលូនៅក្នុងបរិវេណព្រឹទ្ធសភា ដើម្បីបញ្ចៀសការលិចដោយជំនន់ទឹកភ្លៀង

- បានជួសជុល បណ្តាញទឹក ស្តារប្រព័ន្ធលូ ផ្លាស់ប្តូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច

គ្រឿងសង្ហារឹម បិទលេខកូដសម្ភារសារពើភ័ណ្ឌ និងប្រគល់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន១,៦៤៩គ្រឿង/លើក

- បានជួសជុលនៅតាមសាលប្រជុំ អគារសមាជិកព្រឹទ្ធសភា នាយកដ្ឋាននានា និងត្រួតពិនិត្យសត្វកណ្ដៀរ ព្រមទាំងប្រចាំការត្រួតពិនិត្យម៉ាស៊ីនភ្លើង ការប្រើប្រាស់ទឹក ភ្លើងចំនួន១៨០លើក

- បានធ្វើស្លាកលេខរថយន្តព្រឹទ្ធសភាថ្មីជូនសមាជិកព្រឹទ្ធសភាចំនួន០២គ្រឿង

- បានរៀបចំបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋថ្នាំគោលរបស់ព្រឹទ្ធសភា

- បានធ្វើសម្រង់ស្ថិតិ បទបង្ហាញ របាយការណ៍ស្ដីពី លទ្ធផលការងារព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំខែមករា ដល់ខែកញ្ញា ប្រចាំឆមាសទី១ និងប្រចាំនព្វមាស ឆ្នាំ២០២១ ព្រមទាំងបានផ្សព្វផ្សាយទៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងក្រសួងស្ថាប័ននានា

- បានធ្វើរបាយការណ៍ស្ដីពី ការពិនិត្យ និងតាមដានការអនុវត្តផែនការប្រតិបត្តិរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាប្រចាំត្រីមាសទី១ ទី២ និងទី៣ ឆ្នាំ២០២១។

**៩.២-ការងារស្រាវជ្រាវ៖**

- បានស្រាវជ្រាវ និងផលិតឯកសារផ្សេងៗពាក់ព័ន្ធនឹងអាស៊ាន សេដ្ឋកិច្ច សង្គម បរិស្ថាន និងផលប៉ះពាល់នៃជំងឺកូវីដ-១៩ ចំនួន២៣ប្រធានបទ

- បានតាមដានការងារកំណែទម្រង់ និងគោលនយោបាយនានារបស់រាជរដ្ឋាភិបាលពាក់ព័ន្ធនឹងសេដ្ឋកិច្ច កញ្ចប់ថវិកា ចំណូល-ចំណាយ និងបំណុលសាធារណៈចំនួន១០អត្ថបទ

- បានផលិតព័ត៌មានច្បាប់ជាតិ-អន្តរជាតិ និងនយោបាយចំនួន៩៨៨អត្ថបទ

- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ចប្រចាំខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ ចំនួន៣៦ច្បាប់។

**៩.៣-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានរៀបចំទិន្នន័យច្បាប់ (Legal Database) របស់ព្រឹទ្ធសភា

- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធ Network Internet Wi-Fi, ជួសជុលម៉ាស៊ីនកុំព្យូទ័រ Laptop Ipad Smart Phone, ដាក់កម្មវិធីកម្ចាត់មេរោគ Update Files Antivirus និងSetup Window Printer Program Ipad ព្រមទាំងបានដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញបច្ចេកវិទ្យាព័ត៌មានចំនួន៩៨៩គ្រឿង។ បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពរបស់ថ្នាក់ដឹកនាំសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលើគេហទំព័រព្រឹទ្ធសភា

ចំនួន៧៩៣ប្រធានបទ

- បានទទួល និងរៀបចំសៀវភៅច្បាប់ ឯកសារ និងទស្សនាវដ្ដីចំនួន៦១៧ក្បាល និងព្រឹត្តិបត្រ កាសែតAKPចំនួន១៥០ច្បាប់ ព្រមទាំងបានបោះត្រា ចុះបញ្ជីសៀវភៅ ដាក់លេខកូដសៀវភៅ បិទប័ណ្ណខ្ចី និងសងសៀវភៅចំនួន១,០៨១ក្បាល

- បានបញ្ចូលឯកសារ សៀវភៅច្បាប់ សៀវភៅបោះពុម្ពដោយអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និងជំនាញផ្សេងៗតាម E-Library & NAS ចំនួន១០៥ក្បាល

- បានប្រមូល ដកស្រង់ ចងក្រង និងផ្សព្វផ្សាយព័ត៌មានសង្ខេបប្រចាំថ្ងៃចំនួន២៣៩លើក និងទស្សនព័ត៌មានប្រចាំថ្ងៃចំនួន១៩១លើក

- បានប្រើប្រាស់ E-Mail ជាមធ្យោបាយសម្រាប់ដំណើរការចរន្តឯកសារផ្ទៃក្នុងនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

- បន្តអភិវឌ្ឍបច្ចេកវិទ្យាព័ត៌មាន រដ្ឋបាលអេឡិចត្រូនិច ការប្រើប្រាស់ Zoom ប្រព័ន្ធសំឡេង ការផ្សព្វផ្សាយតាមបណ្ដាញសង្គម បណ្ណាល័យ បណ្ណសារដ្ឋានអេឡិចត្រូនិច ការងារព័ត៌មាន។

### ៥.២-ការងារពិធីការៈ

- បានរៀបចំចាត់ចែងជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជួបពិភាក្សាការងារ ចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន៩៧លើក

- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិចំនួន៩១ច្បាប់

- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែមករា ដល់ខែកញ្ញា ឆ្នាំ២០២១ ចំនួន០៩ច្បាប់។

### ៥.៥-ការងារត្រួតពិនិត្យៈ

- លទ្ធផលនៃការអនុវត្តការងាររបស់អគ្គនាយកដ្ឋានទាំង៥ រយៈពេល៩ខែ ឆ្នាំ២០២១នេះ ឃើញថាៈ ១.មុខងារនីតិកម្មទទួលបាន១០០%, ២.មុខងារតាមដានការអនុវត្តច្បាប់ទទួលបាន២០%, ៣.មុខងារតំណាងទទួលបាន២៥%, ៤.មុខងារសហប្រតិបត្តិការអន្តរជាតិទទួលបាន៥២% និង ៥.មុខងារអភិវឌ្ឍស្ថាប័នទទួលបាន៦៩%។ ដូច្នេះលទ្ធផលនៃការអនុវត្តមុខងារទាំង៥ របស់អគ្គនាយកដ្ឋានទាំង៥ គិតជាមធ្យមសម្រេចបាន៦២% នៃផែនការប្រតិបត្តិឆ្នាំ២០២១

- ការអនុវត្តគោលនយោបាយបានទាន់ពេលវេលាសម្រាប់មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបេសកកម្មក្នុងប្រទេសចំនួន១៣១នាក់, ធ្វើការលើសម៉ោងរដ្ឋបាល ចំនួន១.០២២នាក់, ធ្វើការថ្ងៃឈប់សម្រាកចំនួន២.៥២៦នាក់, លំហែមាតុភាពចំនួន២៥នាក់,

រៀបអាពាហ៍ពិពាហ៍ចំនួន០៧នាក់, សុំប្រាក់វិភាជន៍គ្រួសារចំនួន៣៧នាក់, សុំប្រាក់ឧបត្ថម្ភប្រពន្ធចំនួន១៧នាក់ និងប្រាក់ឧបត្ថម្ភកូនចំនួន៣១នាក់, មន្ត្រីរាជការចូលនិវត្តន៍ចំនួន០៤នាក់, ស្ថិតក្នុងភាពទំនេរគ្មានប្រាក់បៀវត្សចំនួន១១នាក់, ព្រមទាំងបានចុះសាកសួរសុខទុក្ខសមាជិកព្រឹទ្ធសភានិវត្តជន មន្ត្រីលំហែមាតុភាព និងមន្ត្រីជួបគ្រោះថ្នាក់ផ្សេងៗចំនួន១៨នាក់។ ចំពោះការផ្ដល់មូលនិធិសង្គមកិច្ច បានឧបត្ថម្ភដល់មន្ត្រី និងបុគ្គលិកជាប់កិច្ចសន្យាមានជំងឺ ជំងឺកូវីដ-១៩ រស់នៅក្នុងតំបន់ក្រហម ចត្តាឡីស័ក ទទួលមរណភាព និងគ្រោះថ្នាក់ផ្សេងៗសរុបចំនួន២៦៦នាក់។ ជារួមការអនុវត្តគោលនយោបាយនានា រក្សាបាននូវតម្លាភាពគណនេយ្យភាព ផ្ដល់ផលប្រយោជន៍ និងលើកទឹកចិត្តដល់មន្ត្រីរាជការ។

**II-លទ្ធផលការងារគាំទ្រលើមុខងារទាំង៥៖**

- បានពិនិត្យ ផ្ដល់យោបល់ និងចុះហត្ថលេខាលើឯកសារផ្សេងៗចំនួន១,៦១២ច្បាប់
- បានតុបតែងលម្អ តាំងពិព័រណ៍រូបភាព ធ្វើហ្វុងអក្សរ ចងបដា ពាក្យស្លោក និងចងទង់ជាតិចំនួន៨២លើក
- បានធ្វើលិខិតបេសកកម្មជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន២៤១ច្បាប់ ស្មើនឹង៧៣៨នាក់, លិខិតអនុញ្ញាតច្បាប់ជូនសមាជិកព្រឹទ្ធសភាចំនួន២៣ច្បាប់ ស្មើនឹង២៣នាក់, លិខិតឧទ្ទេសនាម និងលិខិតបេសកកម្មជូនថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មកប្រចាំការនៅពេលបិទខ្ទប់ការធ្វើដំណើរក្នុងអំឡុងពេលការរីករាលដាលនៃជំងឺកូវីដ-១៩ ចំនួន១៤៧ច្បាប់ ស្មើនឹងចំនួន៧៤២នាក់
- បានផ្ដល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗចំនួន៣,១៦៨លើក
- បានរៀបចំសម្អាត តុបតែងលម្អសាលប្រជុំ ផ្គត់ផ្គង់សម្ភារប្រើប្រាស់ បម្រើសេវាភេសជ្ជៈអាហារសម្រន់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗចំនួន២២៨លើក មានអ្នកចូលរួមចំនួន៤,៩២៣នាក់
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា វគ្គបណ្ដុះបណ្ដាលផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤១៧សំណើ
- បានចែកទឹកអាល់កុលលាងដៃសម្លាប់មេរោគចំនួន២,១២០លីត្រ តាមការស្នើសុំរបស់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- បានថតចម្លងឯកសារចំនួន២៨,៦៣៧ច្បាប់ និងចងក្រងធ្វើជាសៀវភៅចំនួន១,៦៨៣ក្បាល អស់ក្រដាសចំនួន១៩៨,៩៥១សន្លឹក

- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្មនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុង ចំនួន៦៥២លើក ស្មើនឹង២,០៨៥នាក់ ព្រមទាំងបានបង់ពន្ធផ្លូវរថយន្តសម្រាប់ឆ្នាំ២០២១

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាចំនួន៤៥លើក

- បានផលិតខ្សែវីដេអូសមិទ្ធផលរបស់ព្រឹទ្ធសភាចំនួន០៤លើក

- បានថត និងផ្សព្វផ្សាយព័ត៌មានស្តីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធTwitter, Youtube, Facebook, និង Telegramចំនួន២១,៦៤៩លើក

- បានការពារសន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់ក្នុងកិច្ចប្រជុំ និងពិធីផ្សេងៗដោយប្រើប្រាស់កម្លាំងសន្តិសុខផ្ទៃក្នុងចំនួន៤៥លើក។

**III-ទិសដៅការងារសម្រាប់ត្រីមាសទី៤ ឆ្នាំ២០២១**

***-ការគំរាមកំហែងបន្តនៃជំងឺកូវីដ-១៩ ដែលបណ្តាលមកពីមេរោគបំប្លែងខ្លួនថ្មីប្រភេទដែលតា (Delta) ដែលកំពុងបន្តអូសបន្លាយ បានបង្កផលប៉ះពាល់ជាអវិជ្ជមាន សេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន***

***-អនុវត្តវិធានសុខាភិបាលថ្មីតាមរយៈការចាក់វ៉ាក់សាំងលើកទី៣ (ដូសជំរុញ) បន្តអនុវត្តវិធានការ "៣ការពារ ៣កុំ" ពាក់ម៉ាស់ ធ្វើតេស្តពេលចាំបាច់ និងវិធានការចាំបាច់ផ្សេងៗទៀត (ដាក់ឱ្យនៅដាច់ដោយឡែក រឹតត្បិតចត្តាឡីស័ក) ប្រចាំងនឹងជំងឺកូវីដ-១៩ ក្នុងពេលវេលាថ្មីដែលមេរោគប្រភេទដែលតា(Delta) កំពុងរាលដាល និងបន្តយកចិត្តទុកដាក់ធ្វើការងារមនុស្សធម៌ក្នុង និងក្រៅស្ថាប័នឱ្យបានទាន់ពេលវេលា៖***

+យកចិត្តទុកដាក់តាមដានសុខភាពរបស់សមាជិកព្រឹទ្ធសភា

+យកចិត្តទុកដាក់តាមដានសុខភាព លក្ខខណ្ឌការងារ និងជីវភាពទូទៅក្នុងក្របខណ្ឌស្ថាប័នទាំងមូល

+ត្រៀមលក្ខណៈនៃការវិលត្រលប់មកកាន់ភាពប្រក្រតីនៃការអនុវត្តមុខងារស្នូលទាំង៣៖ មុខងារនីតិកម្ម មុខងារតាមដានការអនុវត្តច្បាប់ និងមុខងារតំណាង

+ត្រៀមបត់បែនដើម្បីប្រឈមនឹងការគំរាមកំហែងថ្មីៗ កូវីដ១៩ ជំងឺរាតត្បាតថ្មី គ្រោះធម្មជាតិ ការប្រែប្រួលអាកាសធាតុ ផលវិបាកសេដ្ឋកិច្ច សង្គម វប្បធម៌ បរិស្ថាន សភាពការណ៍តំបន់ និងពិភពលោក ដូចជាអំពើភេរវកម្ម អំពើឧក្រិដ្ឋកម្ម ការវាយប្រហារ និងជំរិតខាងបច្ចេកវិទ្យាព័ត៌មាន

+បន្តយកចិត្តទុកដាក់បរិស្ថាន អនាម័យ សួនច្បារ សំរាម ហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត បច្ចេកទេស បច្ចេកវិទ្យា អគារការិយាល័យ សុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

+សមត្ថភាពប្រើប្រាស់ និងថែទាំបច្ចេកទេស គ្រប់គ្រងការប្រើប្រាស់កម្លាំង និងបច្ចេក-វិទ្យាព័ត៌មានឱ្យបានសមស្របតាមការប្រែប្រួល និងតម្រូវការថ្មី ដោយធានាបានសន្តិសុខ សុវត្ថិភាព វឌ្ឍនភាព និងនិរន្តរភាព

+បច្ចុប្បន្នភាពក្បាលម៉ាស៊ីនដឹកនាំគ្រប់គ្រង ដែលទំនេរដោយមូលហេតុនៃការចូលនិវត្ត

**-បន្តប្រក្រតីភាព និងនិរន្តរភាពការងាររបស់ស្ថាប័នលើគ្រប់វិស័យ និងមុខងារទាំង៤ ក្នុងលក្ខណៈបត់បែន ទន់ភ្លន់ក្នុងសភាពការណ៍ចល័ត ដើម្បីធានាបរិមាណ និងគុណភាពការងារ។ វត្តមានមន្ត្រី បុគ្គលិកត្រូវបន្តឈរលើគោលការណ៍វត្តមានតិចបំផុត២% តែអាចបង្កើនបាន បើមានការចាំបាច់បន្ទាន់ ឬសំខាន់បំផុត៖**

+ធានានិរន្តរភាព ប្រក្រតីភាព ប្រសិទ្ធភាព សុវត្ថិភាពនៃការដឹកនាំ និងគ្រប់គ្រងប្រព័ន្ធការងាររដ្ឋបាល ហិរញ្ញវត្ថុ បច្ចេកទេស ព័ត៌មាន សន្តិសុខ បច្ចេកវិទ្យា នីតិវិធី ពិធីការ ការស្រាវជ្រាវ ទំនាក់ទំនងក្នុង-ក្រៅស្ថាប័ន និងក្នុង-ក្រៅប្រទេស ព្រមទាំងជំនួយកិច្ចសហប្រតិបត្តិការនានា

-ត្រៀមផ្តល់ការិយាល័យ ស្វាករថយន្ត ប័ណ្ណសមាជិក និងរបបមូលដ្ឋានសម្រាប់លោកជំទាវ **ទេព្វ សំអួន** សមាជិកាថ្មី

-ដំណើរវេត្តាះទៅកាន់មូលដ្ឋានរបស់ព្រឹទ្ធសភា ក្នុងរយៈពេលវិស្សមកាល ចាប់ពីថ្ងៃទី០១ ខែតុលា ឆ្នាំ២០២១ ដល់ថ្ងៃទី០១ ខែមករា ឆ្នាំ២០២២

-បង្កើនគុណភាព និងប្រសិទ្ធភាពផ្តល់សេវាជូនសមាជិកព្រឹទ្ធសភា ឱ្យបានល្អប្រសើរ និងគ្រប់ជ្រុងជ្រោយក្នុងដំណើរចុះទៅមូលដ្ឋាន និងជួបសវនាការជាមួយក្រសួង ស្ថាប័ននានា

-ត្រៀមសហការធ្វើរបាយការណ៍ចន្លោះសម័យប្រជុំលើកទី៧ និងទី៨ ឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។

**១- មុខងារនីតិកម្ម**

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា និងសម័យប្រជុំវិសាមញ្ញព្រឹទ្ធសភា នីតិកាលទី៤ ដើម្បីពិនិត្យ និងឱ្យយោបល់លើសេចក្តីព្រាងច្បាប់ចំនួន០៤ច្បាប់ ដូចខាងក្រោម៖

១-សេចក្តីព្រាងច្បាប់ធម្មនុញ្ញស្តីពី វិសោធនកម្មមាត្រា១៩ថ្មី មាត្រា៨២ថ្មី មាត្រា១០៦ ថ្មី(មួយ) មាត្រា១១៩ថ្មី និងមាត្រា១៣៧ថ្មី នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងមាត្រា៣ និងមាត្រា៤ នៃច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ

២-សេចក្តីព្រាងច្បាប់ស្តីពី ភាពជាដៃគូរវាងរដ្ឋ និងឯកជន

៣-សេចក្តីព្រាងកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល (២០២២-២០២៤)

៤-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងបន្ថែមទៅលើកិច្ចព្រមព្រៀងរវាងរាជរដ្ឋាភិបាលកម្ពុជា និងអង្គការសហប្រជាជាតិទាក់ទងទៅនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជានូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យស្តីពី ការរៀបចំក្នុងពេលអន្តរកាល និងការបញ្ចប់ការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ។

**២- មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា**

-ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា ជួបសវនាការ ពិភាក្សាការងារជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធនានា និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា។

**៣- មុខងារតំណាង**

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចូលរួមពិធីបុណ្យជាតិសំខាន់ៗ៖ ពិធីគោរពព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដ្ឋ, បុណ្យកឋិន, ព្រះរាជពិធីគ្រងព្រះបរមរាជសម្បត្តិ, ពិធីបុណ្យឯករាជ្យជាតិ, ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក

-ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភា អញ្ជើញចុះទៅប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី និងចុះចែកអំណោយជូនប្រជាពលរដ្ឋនៅមូលដ្ឋាន ព្រមទាំងចូលរួមពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្ត ក្រុងនានា៖

+ត្រៀមពិធីសម្ពោធសមិទ្ធផលវត្តព្រែកជ្រៃ នៅខណ្ឌដង្កោ និងវត្តកោះមេត្តាពោធិ៍វង្ស នៅខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ។

**៤- មុខងារសហប្រតិបត្តិការអន្តរជាតិ**

-ត្រៀមរៀបចំជំនួបតាមប្រព័ន្ធវីដេអូរវាងថ្នាក់ដឹកនាំជាន់ខ្ពស់ព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជាជាមួយថ្នាក់ដឹកនាំជាន់ខ្ពស់ក្រុមប្រឹក្សានយោបាយប្រជាជនចិននៃសាធារណរដ្ឋប្រជាមានិតចិន

-ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត វេទិកានានា ការងារពិធីការជាតិ និងស្ថាប័ន កម្មវិធីជំនួប កម្មវិធីផ្លូវការ និងសាសនា ការស្វែងរកជំនួយ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ អភិវឌ្ឍស្ថាប័ន ការបណ្តុះបណ្តាលធនធានមនុស្សតាមការកំណត់ និងក្នុងលក្ខណៈបត់បែន ជាការតម្រូវនៃបរិបទកូវីដ-១៩៖

+ផ្តោតអាទិភាពលើការរៀបចំប្រជុំ (ASEP), (CLV) និង(AIPA) ដែលសភាកម្ពុជាជាម្ចាស់ផ្ទះ។ សហការរៀបចំវគ្គសិក្សា២ ដែលព្រឹទ្ធសភាត្រូវរៀបចំជាមួយ (APF) នាចុងខែតុលា និងដើមខែវិច្ឆិកា ព្រមទាំង(ITECH), (MFA)...ចាប់ពីខែសីហា។ តាមដានបញ្ហាចុះហត្ថលេខាលើអនុស្សរណៈ យោគយល់គ្នា(MOU)ជាមួយឥណ្ឌា និងប៉ាគីស្ថាន កម្មវិធីវិទ្យាស្ថានក្រសួងការបរទេស និង វិទ្យាស្ថានចក្ខុវិស័យអាស៊ី។ ការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ឡើងវិញ ជាមួយដៃគូសំខាន់ៗរបស់(PCA) ជាមួយរដ្ឋសភា ព្រឹទ្ធសភាបារាំង លេខាធិការដ្ឋាន(APF) លេខាធិការដ្ឋាន(AIPA) និង(KPI) ព្រមទាំងដៃគូថ្មីមួយចំនួនទៀត (វិទ្យាស្ថានសភាឡាវ)។ តាមដានការអនុវត្តជំនួយចិន សម្រាប់បណ្ណាល័យអេឡិចត្រូនិច និងគម្រោងអភិវឌ្ឍបច្ចេក-វិទ្យាព័ត៌មាន

-ត្រៀមសហប្រតិបត្តិការជាមួយមជ្ឈមណ្ឌលសភាអាស៊ី(PCA) តាមការអនុវត្តកម្មវិធី បណ្តុះបណ្តាលជំហានដំបូង

-ត្រៀមរៀបចំការប្រជុំជូនក្រុមយន្តការនានារបស់ព្រឹទ្ធសភាតាមប្រព័ន្ធវីដេអូ

-ការឈានទៅបង្កើតក្រុមជាតិ(ASEP) រវាងរដ្ឋសភា និងព្រឹទ្ធសភា។ ការធ្វើបច្ចុប្បន្នភាពក្រុមនានា ក្រោយការផ្លាស់ប្តូរសមាជិកព្រឹទ្ធសភា

-ត្រៀមបែបបទចាំបាច់សម្រាប់ការរៀបចំប្រជុំ (ASEP) នាខែវិច្ឆិកាខាងមុខ និងការងារត្រៀមប្រជុំ

-បន្តសកម្មភាពសហប្រតិបត្តិការជាមួយដៃគូនានា ដើម្បីអនុវត្តយុទ្ធសាស្ត្រថវិកាតិច សកម្មភាពច្រើន

-សហការជាមួយដៃគូសំខាន់ៗ អនុវត្តកម្មវិធីសហប្រតិបត្តិការ (PCA, ITECH, MFE, APF) និងបន្តស្វែងរកជំនួយសម្រាប់អភិវឌ្ឍស្ថាប័ន ធនធានមនុស្ស និងបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងការ ចូលរួមមហាសន្និបាត និងវេទិកានានាក្នុងក្របខណ្ឌ (IPU, APF, AIPA, ASEP...)។

**៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន**

-ការបញ្ចប់ផែនការការងារដំណាច់ឆ្នាំ បូកសរុប និងលើកទិសដៅឆ្នាំថ្មី

-ត្រៀមរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា(MOU)ស្តីពី កិច្ចសហ-ប្រតិបត្តិការស្រាវជ្រាវ និងបណ្តុះបណ្តាលធនធានមនុស្សរវាងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជាមួយរាជបណ្ឌិត្យសភាកម្ពុជា

-រយៈពេលបង្កើនការរឹតខ្សែក្រវ៉ាត់ ដោយវិធានការរិចារណកម្មថវិកា ក្នុងឆមាសទី២ ឆ្នាំ២០២១,

ការកសាងថវិកាឆ្នាំថ្មី២០២២ ដោយគិតដល់តម្រូវការក្នុងអំឡុងពេលបោះឆ្នោតថ្នាក់ឃុំ-សង្កាត់ ក្នុងឆមាសទី១ ឆ្នាំ២០២២៖ សម្ពាធនៃតម្រូវការអនុវត្តភាពតំណាងរបស់ព្រឹទ្ធសភា អនុវត្តស្វែងរកជំនួយចិន និងដៃគូ ដើម្បីចាប់ផ្តើមអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៃបច្ចេកវិទ្យាព័ត៌មានរបស់ស្ថាប័ន បន្ទាប់ពីមជ្ឈមណ្ឌលប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ត្រូវបានសាងសង់រួច

-ការត្រៀមរៀបចំបែងចែក និងប្រើប្រាស់ថវិកាព្រឹទ្ធសភាឆ្នាំ២០២២ សម្រាប់រចនាសម្ព័ន្ធនយោបាយ និងរដ្ឋបាល

-ការបើកប្រាក់បៀវត្ស ប្រាក់ឧបត្ថម្ភ និងផលប្រយោជន៍ផ្សេងៗរបស់សមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការសម្រាប់៣ខែចុងឆ្នាំ ឱ្យបានទាន់ពេលវេលា

-យកចិត្តទុកដាក់អនុវត្តគោលការណ៍ 3E's ដោយផ្តោតលើការងារជាអាទិភាព សំខាន់ ចាំបាច់ និងបន្ទាន់បំផុត៖

+ការវិនិយោគលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងវិស័យបច្ចេកទេស គឺជាស្នូលសំខាន់នៃការអភិវឌ្ឍស្ថាប័ន និងការលើកកម្ពស់សមត្ថភាពលើគ្រប់វិស័យ ព្រមទាំងជំនាញរបស់មន្ត្រីបុគ្គលិក

+សមត្ថភាពដឹកនាំ គ្រប់គ្រងនៅតែជាតម្រូវការបន្ទាន់ អាស្រ័យដោយកង្វះខ្វះ អ្នកត្រូវបន្តវេននៅរកពុំទាន់បានតាមតម្រូវការនៃមុខតំណែង

+ធ្វើតបញ្ចូលការប្រើប្រាស់គ្រឿងយន្តអគ្គិសនី និងពង្រីកការបំភ្លឺដោយថាមពលព្រះអាទិត្យ ដើម្បីថែរក្សាធម្មជាតិបៃតង កាត់បន្ថយចំណាយ និងការប្រើកម្លាំងមនុស្ស ហើយចាប់ផ្តើមអនុលោមតាមបរិបទបរិស្ថានទំនើប ដែលប្រឆាំងការប្រែប្រួលអាកាសធាតុ (ការគ្រប់គ្រងសំរាម និងផ្លាស្ទិក)

-អនុវត្តការងារ៣ខែចុងឆ្នាំ តាមបរិបទកូវីដ-១៩ ដោយសម្រេចឱ្យបាននូវការងារជាអាទិភាព កសាងថវិកាឆ្នាំ២០២២ លើកផែនការ និងកម្មវិធីការងាររបស់ស្ថាប័ន និងគ្រប់អង្គភាពឆ្នាំ២០២២។ ការបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ និងការទូទាត់ថវិកាប្រចាំឆ្នាំ ត្រូវអនុវត្តទាន់ពេលវេលា ដោយស្មារតីទទួលខុសត្រូវ៖

+របាយការណ៍ចំណូល-ចំណាយថវិកាព្រឹទ្ធសភាឆ្នាំ២០២១ និងវិភាជន៍គម្រោងថវិកាព្រឹទ្ធសភាឆ្នាំ២០២២ ដើម្បីផ្តល់យោបល់សម្រេចក្នុងរចនាសម្ព័ន្ធរដ្ឋបាល និងនយោបាយ

+ការបោះពុម្ពទិនានុប្បវត្តិ ប្រតិទិន ប័ណ្ណរថយន្ត ត្រូវជានាគុណភាព និងបរិមាណ សមស្របកម្មវិធីបុណ្យជាតិ(បុណ្យឯករាជ្យ) បុណ្យប្រពៃណី (កឋិនទាន) និងកម្មវិធីផ្សេងៗ ទៀតត្រូវជានាការអនុវត្តឱ្យបានទាន់ពេលវេលា

+ជំរុញការកសាងខ្សែវីដេអូអំពីប្រវត្តិទីស្ថានអគារប្រវត្តិសាស្ត្ររបស់ព្រឹទ្ធសភា

-ធ្វើសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ ធនធានមនុស្ស តម្រូវការ និងការប្រឈមៈ គោលការណ៍តមជ្រើសរើសថ្មីរហូតឆ្នាំ២០៣០ ការតម្លើងកាំប្រាក់ មុខតំណែង សន្ទស្សន៍បៀវត្សត្រូវរក្សាស្ថានភាពដដែលរហូតមានការណែនាំថ្មី

-បន្តកសាង និងធ្វើបច្ចុប្បន្នភាព គោលការណ៍ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្តបម្រើឱ្យការគ្រប់គ្រងក្នុងបរិបទកែទម្រង់រដ្ឋបាលសាធារណៈ និងហិរញ្ញវត្ថុសាធារណៈ

-ការអនុវត្តផែនការបណ្តុះបណ្តាលធនធានមនុស្សតាមកិច្ចសហប្រតិបត្តិការជាមួយដៃគូនានាៈ

+៥វគ្គជាមួយភាគីឥណ្ឌា

+វគ្គជាមួយ (PCA)

+វគ្គភាសាអង់គ្លេស ភាសាបារាំង និងថៃជាមួយក្រសួងការបរទេស

+វគ្គភាសាអង់គ្លេសជាមួយស្ថានទូតហ្វីលីពីន

+២វគ្គជាមួយលេខាធិការដ្ឋាន (APF) នាចុងខែតុលា និងដើមខែវិច្ឆិកា

-បញ្ចូលប្រើបច្ចេកវិទ្យា ឧបករណ៍បច្ចេកទេសប្រើអគ្គិសនី (រថយន្តបោសសម្អាត រថយន្តសម្រាប់ឡើងទីខ្ពស់ រថយន្តប្រមូលសំរាម និងរថយន្តលាងសម្អាតផ្លូវ) ការប្រឈមដោះស្រាយបញ្ហាទឹកបន្តលិចផ្នែកខ្លះ ការបង្កើយអគារប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន(ICT) ការចាប់ផ្តើមការដ្ឋានបណ្ណាល័យអេឡិចត្រូនិច ការគ្រប់គ្រងសំរាម និងផ្លាស្ទិក ការរក្សាអនាម័យ និងសួនតាមរបៀបថ្មីរបៀបគិត រស់នៅ និងធ្វើការតាមគន្លងថ្មី ក្រោមការរាតត្បាតជាសកលនៃជំងឺកូវីដ-១៩ និងតាមរបៀបប្រែប្រួលអាកាសធាតុ (ដែលកាន់តែក្តៅ កខ្វក់ និងក្រទឹក) ធម្មជាតិប្រែប្រួលតាមរយៈគម្រោងតូចៗ (Pilot Project)។ បច្ចេកវិទ្យាព័ត៌មានកខ្វក់ (ឧបករណ៍ ហេដ្ឋារចនាសម្ព័ន្ធ ស្តុកទិន្នន័យ)។ ជំងឺកូវីដ-១៩ មានការគំរាមកំហែងខ្លះដល់បរិស្ថានផងដែរ។ ពិចារណាការប្រើប្រាស់កម្លាំងពលកម្មឱ្យបានសមស្របដំណាក់កាលថ្មី ដែលមានការប្រែប្រួលជារៀងរាល់ថ្ងៃ។

-ការប្រជុំពីចម្ងាយ ការធ្វើការពីចម្ងាយ និងការរៀនសូត្រពីចម្ងាយ គឺជាឧបករណ៍ថ្មីវិធីសាស្ត្រថ្មីក្នុងបរិបទកូវីដ-១៩ ហើយអាចនៅបន្តក្រោយជំងឺកូវីដ-១៩

-បង្កើនការគ្រប់គ្រងអគារ និងសារពើភ័ណ្ឌ ការគ្រប់គ្រងសន្តិសុខ សណ្តាប់ធ្នាប់ អនាម័យ និងការគ្រប់គ្រងការប្រើប្រាស់ Internet

-ទំនាក់ទំនង និងជំរុញសុំការគាំទ្រពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គម្រោងជំនួយចិនក្នុងការ

សាងសង់ និងបំពាក់សម្ភារមជ្ឈមណ្ឌលប្រព័ន្ធព័ត៌មានវិទ្យា(ICT)

-នាយកដ្ឋានព័ត៌មានវិទ្យា នាយកដ្ឋានស្រាវជ្រាវកិច្ចការអន្តរជាតិ នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស ត្រូវបន្តទំនាក់ទំនងជាមួយដៃគូអភិវឌ្ឍរបស់ខ្លួន (ក្រុមហ៊ុនHuawei វិទ្យាស្ថានជាតិការទូត និងដៃគូបណ្តុះបណ្តាលនានា។ល។)

-បង្កើនគុណភាពនៃការថត និងផ្សព្វផ្សាយអំពីសម័យប្រជុំពេញអង្គព្រឹទ្ធសភា

-បន្តកសាងប្រព័ន្ធគ្រប់គ្រងទិន្នន័យ គ្រប់គ្រងព័ត៌មាន គ្រប់គ្រងរដ្ឋបាល កម្មវិធីបណ្ណសារអេឡិចត្រូនិច និងបណ្ណាល័យអេឡិចត្រូនិច ត្រូវបន្តសហការយ៉ាងសកម្មជាមួយភាគីចិន។

## IV-**សេចក្តីសន្និដ្ឋាន**

ក្នុងនព្វមាសនេះ បរិបទដែលសកលលោក និងប្រទេសកម្ពុជាយើង កំពុងបន្តពួតដៃគ្នាក្នុងការប្រយុទ្ធប្រឆាំង និងយកឈ្នះជំងឺកូវីដ-១៩ ដើម្បីធានានិរន្តរភាពសកម្មភាពសង្គម សេដ្ឋកិច្ច និងការរស់រានមានជីវិតរបស់ប្រជាជន។ ទោះបីស្ថិតក្នុងកាលៈទេសៈលំបាក និងស្មុគស្មាញយ៉ាងណាក៏ដោយ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានខិតខំប្រឹងប្រែងស្វែងរកយន្តការថ្មីៗ និងបត់បែនតាមស្ថានភាពជាក់ស្តែងជារួមបានទទួលលទ្ធផលល្អប្រសើរ។ ទន្ទឹមនឹងនេះ បានផ្តោតការយកចិត្តទុកដាក់ការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការដើម្បីប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាពិសេសថ្នាក់ដឹកនាំ និងមន្ត្រីរាជការទាំងអស់ បានខិតខំប្រឹងប្រែងប្រែក្លាយបញ្ហាប្រឈមឱ្យទៅជាកាលានុវត្តភាពតាមយន្តការប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានលើគ្រប់វិស័យនៃការងារប្រចាំថ្ងៃ រដ្ឋបាលអេឡិចត្រូនិច និងរៀបចំកិច្ចប្រជុំអន្តរជាតិនានា តាមប្រព័ន្ធវីដេអូទាំងផ្ទៃក្នុងស្ថាប័ន ក៏ដូចជាក្របខណ្ឌជាតិ និងអន្តរជាតិ ដើម្បីធានានិរន្តរភាពការងារឱ្យស្របតាមស្ថានភាពជាក់ស្តែង និងតម្រូវការចាំបាច់របស់ស្ថាប័ន និងប្រទេសជាតិ។

សកម្មភាពលេចធ្លោគឺការយកចិត្តទុកដាក់ធ្វើសកម្មភាពឆ្ពោះទៅកាន់មូលដ្ឋាន តាមរយៈការចុះប្រាស្រ័យទាក់ទងជាមួយប្រជាពលរដ្ឋ អាជ្ញាធរដែនដី ការចូលរួមយុទ្ធនាការប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩ និងការយកចិត្តទុកដាក់របស់ថ្នាក់ដឹកនាំ និងសមាជិកព្រឹទ្ធសភាដល់ប្រជាពលរដ្ឋដែលមានជីវភាពខ្វះខាត និងកំពុងធ្វើចត្តាឡីស័ក ការរៀបចំវេទិកា កិច្ចពិគ្រោះយោបល់ ការឈ្វេងយល់អំពីវឌ្ឍនភាពជាវិជ្ជមានក្រោយការរៀបចំវេទិកា ព្រមទាំងការចូលរួមចំណែកដល់ការអភិវឌ្ឍលើគ្រប់វិស័យនៅថ្នាក់ក្រោមជាតិ។

ដើម្បីឱ្យស្របតាមបរិបទនៃការវិវត្តថ្មី ជាពិសេសការធ្វើវិចារណកម្មថវិកាឆ្នាំ២០២១ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ខិតខំពង្រឹងប្រសិទ្ធភាពចំណាយដោយអនុវត្តគោលការណ៍3E's

ដើម្បីជានាប្រក្រតីភាពការអនុវត្តថវិកាឆ្នាំ២០២១ រហូតដល់ដំណាច់ឆ្នាំ ដោយផ្តោតតែលើការងារអាទិភាពដែលចាំបាច់បំផុត សំខាន់បំផុត និងបន្ទាន់បំផុត។

មន្ត្រីរាជការទាំងអស់ ត្រូវបន្តយកចិត្តទុកដាក់ចូលរួមប្រយុទ្ធប្រឆាំងនឹងការរីករាលដាលនៃជំងឺកូវីដ-១៩នេះ ដោយអនុវត្តឱ្យបានខ្ជាប់ខ្ជួនតាមវិធានការរបស់ក្រសួងសុខាភិបាលឱ្យបានម៉ត់ចត់ និងបន្តចូលរួមអនុវត្តវិធានការ "៣ការពារ ៣កុំ" ឱ្យបានល្អប្រសើរ។

ជំងឺកូវីដ-១៩ នៅបន្តជាការគំរាមកំហែងរួមសម្រាប់ពេលខាងមុខនេះ។

ថ្ងៃពុធ ៧កើត ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែតុលា ឆ្នាំ២០២១

**អគ្គលេខាធិការ**

អ៊ុំ_សារិទ្ធ